Washington State Department of
Labor & Industries

# ច្បាប់ស្តីពីសុវត្ថិភាពការងារ និងសុខភាព

## វាជាច្បាប់! និយោជកត្រូវតែបិទសេចក្តីជូនដំណឹងនេះនៅកន្លែងដែលនិយោជិតអាចអានវាបាន។

(ជំពូក 49.17 ក្រមរដ្ឋវ៉ាស៊ីនតោនដែលបានកែសម្រួល [Revised Code of Washington, RCW])

## អ្នកធ្វើការទាំងអស់មានសិទ្ធិធ្វើការនៅកន្លែងការងារមានសុវត្ថិភាព និងមានសុខភាពល្អ។

### **និយោជិត** – និយោជករបស់អ្នកត្រូវតែការពារអ្នកពីគ្រោះថ្នាក់ដែលអ្នកជួបប្រទះនៅលើការងារ ប្រាប់អ្នកអំពីគ្រោះថ្នាក់ទាំងនោះ និងផ្តល់នូវការបណ្តុះបណ្តាល។

**អ្នកមានសិទ្ធិដើម្បី៖**

- ជូនដំណឹងដល់និយោជក ឬ L&I (ក្រសួងការងារ និងឧស្សាហកម្ម) របស់អ្នកអំពីគ្រោះថ្នាក់កន្លែងធ្វើការ។ អ្នកអាចស្នើសុំ L&I ឲ្យទុកឈ្មោះរបស់អ្នកជាសម្ងាត់។
- ស្នើសុំការត្រួតពិនិត្យពី L&I ក្នុងកន្លែងដែលអ្នកធ្វើការប្រសិនបើអ្នកជឿថាវាមានលក្ខណៈគ្មានសុវត្ថិភាព ឬគ្មានសុខភាព។ អ្នក ឬតំណាងនិយោជិតរបស់អ្នកអាចចូលរួមក្នុងការត្រួតពិនិត្យ ដោយគ្មានការខាតបង់ប្រាក់ឈ្នួល ឬអត្ថប្រយោជន៍ទេ។
- ទទួលបានច្បាប់ចម្លងនៃកំណត់ត្រាសុខភាពរបស់លោកអ្នកដោយរួមបញ្ចូលទាំងកំណត់ត្រានៃការប៉ះពាល់ទៅនឹងជាតិពុល និងសារធាតុគ្រោះថ្នាក់ ឬលក្ខខណ្ឌផ្សេងៗ។
- ដាក់ពាក្យបណ្តឹងជាមួយ L&I ក្នុងរយៈពេល 90 ថ្ងៃ ប្រសិនបើអ្នកជឿថានិយោជករបស់អ្នកបានបណ្តេញអ្នកចេញ ឬសងសឹក ឬរើសអើងអ្នក ដោយសារអ្នកបានដាក់ពាក្យបណ្តឹងផ្នែកសុវត្ថិភាព ចូលរួមក្នុងការត្រួតពិនិត្យឬសកម្មភាពដែលទាក់ទងនឹងសុវត្ថិភាពផ្សេងទៀត។
- ប្តឹងឧទ្ធរណ៍កែតម្រូវកាលបរិច្ឆេទនៃការរំលោភបំពាន ប្រសិនបើអ្នកជឿថាពេលវេលាដែលបានអនុញ្ញាតនៅលើសេចក្តីបង្គាប់នោះគឺមិនសមហេតុផល។

**ច្បាប់តម្រូវឱ្យអ្នកអនុវត្តតាមច្បាប់សុវត្ថិភាព និងសុខភាពនៅកន្លែងធ្វើការ ដែលអនុវត្តចំពោះសកម្មភាព និងការប្រព្រឹត្តផ្ទាល់ខ្លួនរបស់អ្នកលើការងារ។**

### **និយោជក** – អ្នកមានកាតព្វកិច្ចផ្លូវច្បាប់ក្នុងការការពារបុគ្គលិកពេលធ្វើការងារ។

**និយោជកត្រូវតែផ្តល់កន្លែងធ្វើការដោយគ្មានគ្រោះថ្នាក់ដែលអាចទទួលយកបាន ដែលអាចបង្កឱ្យបុគ្គលិកមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬស្លាប់។**

**សកម្មភាពដែលអ្នកត្រូវតែធ្វើ៖**

- គោរពតាមច្បាប់សុខភាព និងសុវត្ថិភាពទាំងអស់នៅកន្លែងការងារដែលពាក់ព័ន្ធអាជីវកម្មរបស់អ្នក រួមបញ្ចូលទាំងការអភិវឌ្ឍ និងការអនុវត្តគម្រោងបង្ការគ្រោះថ្នាក់ជាលាយលក្ខណ៍អក្សរ (ត្រូវបានគេហៅថា APP ឬកម្មវិធីសុវត្ថិភាព)។
- បិទប្រកាសសេចក្តីជូនដំណឹងនេះ ដើម្បីជូនដំណឹងដល់និយោជិតរបស់អ្នកនូវសិទ្ធិ និងការទទួលខុសត្រូវរបស់ពួកគេ។
- មុនពេលចាត់តាំងឲ្យធ្វើការងារ ត្រូវបណ្តុះបណ្តាលបុគ្គលិកពីរបៀបបង្ការការប៉ះពាល់គ្រោះថ្នាក់ ហើយផ្តល់ជូននូវឧបករណ៍ការពារផ្ទាល់ខ្លួនដែលតម្រូវឱ្យមានដោយមិនគិតថ្លៃ។
- អនុញ្ញាតឱ្យតំណាងបុគ្គលិកធ្វើការម្នាក់ចូលរួមក្នុងការត្រួតពិនិត្យសុវត្ថិភាព/សុខភាពរបស់ L&I ដោយគ្មានការខាតបង់ប្រាក់ឈ្នួល ឬអត្ថប្រយោជន៍។ អ្នកត្រួតពិនិត្យ L&I អាចនិយាយដោយសម្ងាត់ជាមួយនិយោជិតមួយចំនួន។
- ប្រសិនបើអ្នកត្រូវបានលើកឡើងទាក់ទងនឹងការរំលោភបំពានលើសុវត្ថិភាព និង/ឬសុខភាព អ្នកត្រូវតែបង្ហាញការដកស្រង់យ៉ាងច្បាស់លាស់នៅ ឬជិតកន្លែងដែលមានការរំលោភបំពានបែបនេះក្នុងរយៈពេលយ៉ាងតិចប្រាំពីរថ្ងៃធ្វើការ ដោយមិនរាប់បញ្ចូលថ្ងៃចុងសប្តាហ៍ និងថ្ងៃឈប់សម្រាក។ វាត្រូវតែបន្តផ្តល់ព័ត៌មានរហូតដល់ការរំលោភបំពានទាំងអស់ត្រូវបានកែតម្រូវ។

**ការបណ្តេញចេញពីការងារ ឬការរើសអើងលើនិយោជិតចំពោះ ការដាក់ពាក្យបណ្តឹងណាមួយ ឬចូលរួមក្នុងការត្រួតពិនិត្យ ការស៊ើបអង្កេត ឬការបើកឬបិទសន្និសីទជាការខុសច្បាប់។**

### និយោជកត្រូវតែរាយការណ៍អំពីករណីស្លាប់ទាំងអស់ ការសម្រាកនៅពេទ្យ ការកាត់អវៈយវៈ ឬការបាត់បង់ ភ្នែក។

រាយការណ៍ពីការស្លាប់ដែលទាក់ទងនឹងការងារណាមួយ ឬការស្រមាកនៅក្នុងមន្ទីរពេទ្យទៅកាន់ផ្នែកសុវត្ថិភាពការងារ និងសុខភាព (Division of Occupational Safety and Health, DOSH) របស់ L&I ក្នុងរយៈពេល 8 ម៉ោង។

រាយការណ៍ការកាត់អវៈយវៈក្រៅមន្ទីរពេទ្យដែលទាក់ទងនឹងការងារ ឬការបាត់បង់ភ្នែកទៅកាន់ DOSH ក្នុងរយៈពេល 24 ម៉ោង។

ស្រមាប់ការស្លាប់ដែលទាក់ទងនឹងការងារណាមួយ ការស្រមាកព្យាបាលជំងឺនៅមន្ទីរពេទ្យ ការកាត់អវៈយវៈ ឬការបាត់បង់ភ្នែក អ្នកត្រូវតែរាយការណ៍ព័ត៌មានខាងក្រោមនេះទៅ DOSH៖

- អ្នកទំនាក់ទំនង និងលេខទូរសព្ទរបស់និយោជក។
- ឈ្មោះអាជីវកម្ម។
- អាសយដ្ឋាន និងទីកន្លែង ដែលឧបទ្ទវហេតុទាក់ទងនឹងការងារបានកើតឡើង។
- កាលបរិច្ឆេទ និងពេលវេលានៃឧបទ្ទវហេតុ។
- ចំនួនបុគ្គលិក និងឈ្មោះរបស់ពួកគេ។
- ការពណ៌នាដោយសង្ខេបនូវអ្វីដែលបានកើតឡើង។

**កន្លែងដែលត្រូវរាយការណ៍៖**

- ការិយាល័យ L&I ក្នុងមូលដ្ឋានណាមួយ ឬ
- ទូរសព្ទទៅលេខ 1-800-423-7233 ចុចលេខ 1 (មានស្រមាប់ជួយ 24/7)

ផ្ទាំងរូបភាពនេះអាចរកបានដោយឥតគិតថ្លៃពី L&I នៅ **www.Lni.wa.gov/RequiredPosters**។

**ការផ្តល់ជំនួយឥតគិតថ្លៃពីនាយកដ្ឋានសុវត្ថិភាពអាជីព និងសុខភាព (DOSH)**

- ការបណ្តុះបណ្តាល និងធនធានដើម្បីជួយជំរុញកន្លែងការងារឲ្យមានសុវត្ថិភាព។
- ការពិគ្រោះយោបល់នៅនឹងកន្លែងដើម្បីជួយនិយោជកសម្គាល់ និងដោះស្រាយបញ្ហាគ្រោះថ្នាក់ និងការជួយការគ្រប់គ្រងហានិភ័យដើម្បីកាត់បន្ថយថ្លៃសំណងបុគ្គលិករបស់អ្នក។

Division of Occupational Safety and Health
**www.Lni.wa.gov/go/F416-081-214 | 1-800-423-7233**

*តាមការស្នើសុំ ការជួយ និងទម្រង់ជាភាសាបរទេស សម្រាប់មនុស្ស ដែលមានភាពពិការក៏មានជូនដែរ។ សូមទូរសព្ទទៅ 1-800-547-8367។ អ្នកប្រើ TDD សូមទូរសព្ទទៅកាន់លេខ 711។ L&I ជានិយោជកដែលផ្តល់ឱកាសស្មើគ្នា។*

PUBLICATION F416-081-214 (Cambodian) [07-2022]